N: 40
31-10-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៤០ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I . ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៣_១០_១៩៩៧_ KRET NS/KRT/1097/70 ORDONNONS :
S.A.R. le Prince SISOWATH CHIVAN MONIRAK ESTNOMMÉ HAUT CONSEILLER PRIVÉ DU ROI EN REMPLACEMENT NUMÉRIGUE DE S.E SAMDECH CHAKREY NHIEK TIOULONG DÉCÉDÉ ២៣១៥

២៨_១០_១៩៩៧_ ព្រះរាជក្រឹត្យ ជស/រកត/១០៩៧/២១១ តម្លើងឋានន្តរស័ក្តិ និងតែងតាំងផ្លាស់ប្តូរមុខងារន[illegible]នជាន់ខ្ពស់ក្នុង កងយោធពលខេមរភូមិន្ទ ២៣១៦

២៨_១០_១៩៩៧_ ព្រះរាជក្រឹត្យ ជស/រកត/១០៩២/២១២ តែងតាំងមន្ត្រី ៣រូប នៃក្រសួងពាណិជ្ជកម្ម ២៣១៩

២៩_១០_១៩៩៧_ ព្រះរាជក្រឹត្យ ជស/រកត/១០៩៧/២១៣ តែងតាំងឥស្សរជន អោយមានឋានន្តរស័ក្តិថ្នាក់អនុរដ្ឋលេខាធិការ ២៣២១

២៩_១០_១៩៩៧_ ព្រះរាជក្រឹត្យ ជស/រកត/១០៩៧/២១៤ តែងតាំងឯកឧត្តម លឹម សំកុល ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ២៣២៣

២៩_១០_១៩៩៧_ ព្រះរាជក្រឹត្យ ជស/រកត/១០៩៧/២១៥ តែងតាំងឯកឧត្តម ព្រហ្ម សិទ្ធត្រា ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ២៣២៤

II_ រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៤_១០_១៩៩៧_ អនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្តីពីការកំណត់ភារកិច្ចកំណត់ ភារកិច្ចបន្ថែម ភារកិច្ចថ្នាក់តួប និងប្រាក់កំរៃសំរាប់ការបង្រៀន ក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ២៣២៥
២៤_១០_១៩៩៧_ អនុក្រឹត្យលេខ ៧០ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការ ជាតិអូឡាំពិកសំរាប់ជនពិការកម្ពុជា ២៣២៨
២៨_១០_១៩៩៧_ អនុក្រឹត្យលេខ ៧១ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្ត ទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន ២៣៣០
២៩_១០_១៩៩៧_ អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីការបង្កើតក្រុមហ៊ុន ចំការកៅស៊ូពាមជាំង ២៣៤១
២៨_១០_១៩៩៧_ អនុក្រឹត្យលេខ ២១០ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច នាយនគរបាលជាតិ ២៣៤៣

២_ សេចក្តីសំរេច

២៩_១០_១៩៩៧_ សេចក្តីសំរេចលេខ ៤២ សសរ ស្តីពីការផ្ទេរសិទ្ធិ ២៣៤៤

III - ការងារបណ្តាក្រសួង

១_ទីស្តីការគណៈរដ្ឋមន្ត្រី

ប្រកាស

២៧_១០_១៩៩៧_ ប្រកាសលេខ ១៥១ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៤៦
២៧_១០_១៩៩៧_ ប្រកាសលេខ ១៥១ស្ទួន ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៤៧

២_ ធនាគារជាតិ នៃកម្ពុជា

២៥_១០_១៩៩៧_ ប្រកាសលេខ ធ ៧៩៦_១៥៣ Bis ប្រក ស្តីពីអាជ្ញាធរប័ណ្ណរបស់ធនាគារដែលបង្កើតឡើង ក្រោមទំរង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុក ២៣៤៨

៣_ ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

២៧_១០_១៩៩៧_ ប្រកាសលេខ ៣១៤ ពណ.ពកប.ប្រក ផ្តល់វិញ្ញាបនបត្រដើមទំរង់ «A» ជូនដល់ក្រុមហ៊ុនកាត់ដេរ ២៣៥៧

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

២៤_១០_១៩៩៧_ ប្រកាសលេខ ២៨៨/៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៥៩
២៤_១០_១៩៩៧_ ប្រកាសលេខ ២៨៩/៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៦០
២៤_១០_១៩៩៧_ ប្រកាសលេខ ២៩០/៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៦១
២៤_១០_១៩៩៧_ ប្រកាសលេខ ២៩១/៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៦២
២៤_១០_១៩៩៧_ ប្រកាសលេខ ២៩២/៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៦៣

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

KRET

NS/KRT/1097/70

NOUS

NORODOM SIHANOUK
ROI DU CAMBODGE

ORDONNONS :

S.A.R. le Prince SISOWATH CHIVAN MONIRAK

est nommé

Haut-CONSEILLER Privé du ROI ,

en remplacement numérique de S.E. Samdech Chakrey NHIEK TIOULONG,

décédé .

Signature

NORODOM SIHANOUK

Fait à Siemreap-Ankor ,

le 23 Octobre 1997

ព្រះរាជក្រឹត្យ នស/រកត/១០៩៧/២១១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧបតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាព នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២ និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ត្រាស់បង្គាប់

មាត្រា១. – ត្រូវបានតម្លើងឋានន្តរសក្តិ និងតែងតាំងផ្លាស់ប្តូរមុខងារនាយទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែល មានរាយនាមដូចខាងក្រោម ៖

ក– តម្លើងឋានន្តរសក្តិ ជាឧត្តមសេនីយទោ

១– លោកឧត្តមសេនីយត្រី ជា ម៉ន អត្តលេខ ០០០១៣៥ មេបញ្ជាការរងយោធភូមិភាគទី៤ បច្ចុប្បន្នជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ និងមេបញ្ជាការយោធភូមិភាគទី៤

២– លោកឧត្តមសេនីយត្រី ខូ ឈាន អត្តលេខ ០០០១៤៣ មេបញ្ជាការរងយោធភូមិភាគទី៥ បច្ចុប្បន្នជាទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រីទី ២ និងជាមេបញ្ជាការយោធភូមិ ភាគទី ៥

៣_លោកឧត្តមសេនីយ៍ត្រី ម៉ឺន សេង អត្តលេខ ០០០១៤៥ មេបញ្ជាការរងយោធភូមិភាគទី៥ បច្ចុប្បន្នជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ និងជាមេបញ្ជាការរងទី១ យោធភូមិភាគទី៥

ខ_ តម្លើងឋានន្តរសក្តិ ជាឧត្តមសេនីយ៍ត្រី

១_លោកវរសេនីយឯក ឯក សំអុន អត្តលេខ ០០០៦៦៨ នាយរងការិយាល័យទី៣ អគ្គសេនាធិការ បច្ចុប្បន្នជានាយសេនាធិការយោធភូមិភាគទី ៥

២_លោកវរសេនីយឯក ចាប តុក្លី អត្តលេខ ០០០៤៣០ មេបញ្ជាការកងឯកភាព ៩១១ ឆ័ត្រយោង អគ្គសេនាធិការ

៣_លោកសេនីយឯក ទុំ សោភ័ណ្ឌ អត្តលេខ ០០០២៦៧ នាយរងអធិការកិច្ច អគ្គសេនាធិការ បច្ចុប្បន្នជានាយរងអធិការកិច្ច អគ្គបញ្ជាការដ្ឋាន

៤_លោកវរសេនីយឯក ចាន់ សុខុម អត្តលេខ ០០០២៨៦ នាយរងការិយាល័យយោធាតំបន់ អគ្គសេនាធិការ បច្ចុប្បន្នជានាយរងទីចាត់ការការងារហ្វឹកហ្វឺន អគ្គបញ្ជាការដ្ឋាន

គ_ តម្លើងឋានន្តរសក្តិ ជាឧត្តមនាវីត្រី

១_លោកវរសេនីយឯក ឌេត ទិចិត្រ អត្តលេខ ០០០២៨៤ នាយរងការិយាល័យទី៥ អគ្គសេនាធិការ បច្ចុប្បន្នជាមេបញ្ជាការរងកងនាវាចរ ។

ឃ_ តែងតាំងផ្លាស់ប្តូរមុខងារ

១_លោកឧត្តមសេនីយទោ ទឹម សោភ័ណ្ឌ អត្តលេខ ០០០០៣៣ នាយករងអគ្គសេនាធិការ បច្ចុប្បន្ន បន្ថែមមុខងារជាទីប្រឹក្សាសហអគ្គមេបញ្ជាការ

២_លោកឧត្តមសេនីយទោ ហ៊ុល សាវ័ន្ត អត្តលេខ ០០០០៥២ នាយកទីចាត់ការការងារភស្តុភារ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នបន្ថែមមុខងារជាទីប្រឹក្សាសហអគ្គមេបញ្ជាការ

៣_លោកឧត្តមសេនីយទោ ទុំ សម្បុរ អត្តលេខ ០០០០៤៤ ទីប្រឹក្សាសម្តេច ក្រុមព្រះ ទទួលបន្ទុកកិច្ចការយោធា បច្ចុប្បន្នជាទីប្រឹក្សាឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ ទទួលបន្ទុកកិច្ចការយោធា

=

៤_អ្នកឧកញ៉ាម្ចាស់ឧត្តមសេនីយទោ នរោត្តម ចាន់ ចាន់នី អត្តលេខ ០០០០៣៤ មេបញ្ជាការកងទ័ពអាកាស ខ.ភ.ម បច្ចុប្បន្នជាទីប្រឹក្សាក្រសួងការពារជាតិ

៥_លោកឧត្តមសេនីយទោ ផាន់ ខួន អត្តលេខ ០០០០៤៩ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ បច្ចុប្បន្ន បន្ថែមមុខងារជា មេបញ្ជាការទ័ពអាកាស ខ.ភ.ម

៦_លោកឧត្តមសេនីយត្រី ព្រហ្ម មរណៈ អត្តលេខ ០០០១៤៤ មេបញ្ជាការរងយោធភូមិភាគទី ៥ បច្ចុប្បន្នជា មេបញ្ជាការរងយោធភូមិភាគទី ៤

៧_លោកឧត្តមសេនីយត្រី ស សារឿន អត្តលេខ ០០០១៦០ នាយករងទីចាត់ការហិរញ្ញ សហអគ្គមេបញ្ជាការ បច្ចុប្បន្នជាមេបញ្ជាការរងយោធ ភូមិភាគទី ៤

៨_លោកឧត្តមសេនីយត្រី ស៊ូ ម៉េត អត្តលេខ ០០៣៨០៧ ទីប្រឹក្សាក្រសួងការពារជាតិ បច្ចុប្បន្នបន្ថែមមុខងារជា មេបញ្ជាការរងយោធភូមិភាគទី ៥

៩_លោកឧត្តមសេនីយត្រី មាស សំអឿន អត្តលេខ ០០០៣៩៤ នាយសេនាធិការយោធភូមិភាគទី ៥ បច្ចុប្បន្នជា មេបញ្ជាការកងពលធំលេខ ១២

១០_លោកឧត្តមសេនីយត្រី ឡុង ថែម អត្តលេខ ០០៣៨០៩ មេបញ្ជាការរងយោធភូមិភាគទី៤ បច្ចុប្បន្នជា ទីប្រឹក្សាក្រសួងការពារជាតិ

១១_លោកឧត្តមសេនីយត្រី ខណ្ណ សុផាត អត្តលេខ ០០០១៣៣ មេបញ្ជាការរងយោធភូមិភាគទី ៤ បច្ចុប្បន្នជា មេបញ្ជាការរងយោធភូមិភាគទី ៥

១២_លោកឧត្តមសេនីយត្រី ចាន់ ម៉ុននី អត្តលេខ ០០០១០៤ មេបញ្ជាការរងកងរាជអាវុធហត្ថ បច្ចុប្បន្នជានាយករង ទីចាត់ការការងារហិរញ្ញ អគ្គបញ្ជាការដ្ឋាន

មាត្រា២.– នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.–ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះសហ្គលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា ហត្ថលេខា

អ៊ុង ហួត ហ៊ុន សែន

ជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និង

សម្តេចនាយករដ្ឋមន្ត្រីទី២

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ទៀ បាញ់ ឆា ថីវ៉ាត់

* * *

ព្រះរាជក្រឹត្យ ជស/រកត/១០៩៧/២១២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧបតសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

–បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

–បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

_បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី

_បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម

_បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការកែ សំរួលសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា

_តាមសេចក្តីក្រាបបង្គំទូលថ្វាយពីនាយករដ្ឋមន្ត្រីទាំងពីរ

ត្រាស់បង្គាប់

មាត្រា១._ត្រូវតែងតាំងមន្ត្រី ០៣រូប នៃក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាង ក្រោម ÷

១_លោក **គឹម ស៊ីថន** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួង ពាណិជ្ជកម្ម

២_លោក **ម៉ៅ ថូរ៉ា** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួង ពាណិជ្ជកម្ម

៣_លោក **លឹម សំអាត** ជាអគ្គាធិ   គ្គាធិការដ្ឋាន ក្រសួងពាណិជ្ជកម្ម

មាត្រា២._នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា៣._ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហត្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស/រកត/១០៩៧/២១៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាព នៃរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីនាយករដ្ឋមន្ត្រីទាំងពីរ

ត្រាស់បង្គាប់

មាត្រា១.– តែងតាំងឥស្សរជនអោយមានឋានន្តរសក្តិថ្នាក់អនុរដ្ឋលេខាធិការ ដូចមានរាយនាមខាងក្រោម ÷

១– ឯកឧត្តម ស៊ុយ ម៉ុងឈាង	អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជំនួសលោកជំទាវ ប៉ុក ម៉ារីណា
២– ឯកឧត្តម ស្លា ប្រយុទ្ធ	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ជំនួសឯកឧត្តម លី ធុច
៣– ឯកឧត្តម កែម សុខណៃ	អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម (តម្លើងថ្មី)
៤– ឯកឧត្តម លឹម សុភាព	អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម (តម្លើងថ្មី)

៥_ឯកឧត្តម យឹម ឡើនថន	អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំនួស ឯកឧត្តម ម៉ៅ សំអឿន
៦_ឯកឧត្តម ឈឹម គានហោ	អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ថែមលើមុខងារបច្ចុប្បន្ន (តម្លើងឋានៈ)
៧_ឯកឧត្តម ជាច ឡើន	អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (តម្លើងថ្មី)
៨_ឯកឧត្តម ឃាន សុផល	អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ជំនួសឯកឧត្តម អ៊ុំស្វាងឈ ខ្សាន់
៩_ឯកឧត្តម គេង សេង	អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល (តម្លើងថ្មី)
១០_ឯកឧត្តម សេង លឹមនៅ	អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល (តម្លើងថ្មី)
១១_ឯកឧត្តម លី យីថុន	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ជំនួសឯកឧត្តម ទ្រួច យឿម
១២_ឯកឧត្តម សាន់ឌី ជីម៉ុងតេរ៉ូ	អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា (តម្លើងថ្មី)
១៣_ឯកឧត្តម ជ័យ ចាប	អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា (តម្លើងថ្មី)
១៤_ឯកឧត្តម សូ សាមុត	អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ជំនួស លោកជំទាវ នួន សូភា
១៥_ឯកឧត្តម ឡា ណារ៉ាត	អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (តម្លើងថ្មី)
១៦_ឯកឧត្តម គង់ សេង	អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (តម្លើងថ្មី)
១៧_ឯកឧត្តម ពូ សុមច្ចនា	អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ជំនួសឯកឧត្តម សុខ ចិន្តា
១៨_ឯកឧត្តម នាង ណារិន	អនុរដ្ឋលេខាធិការក្រសួងផែនការ (តម្លើងថ្មី)
១៩_ឯកឧត្តម អ៊ុក ចាយ	អនុរដ្ឋលេខាធិការក្រសួងផែនការ (តម្លើងថ្មី)

មាត្រា២._ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូល

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/១០៩៧/២១៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

_បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

_បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

_បានឃើញ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាល កម្ពុជា ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា១._ត្រូវតែងតាំង ឯកឧត្តម **ឈឹម សំគុល** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានឋានៈស្មើនឹង **អនុរដ្ឋលេខាធិការ** ។

មាត្រា២.– នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.– ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/១០៩៧/២១៥

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

– បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

– បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧

ប្រកាសបង្គាប់

មាត្រា១._ត្រូវតែងតាំងឯកឧត្តម **ឡាយ សិទ្ធិត្រា** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានឋានៈស្មើនឹង **អនុរដ្ឋលេខាធិការ** ។

មាត្រា២._នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា៣._ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ ចាប់ពីថ្ងៃឡាយព្រះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

II-រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

អនុក្រឹត្យលេខ ៦៩ អនក្រ.បក

ស្តីពីការកំរិតភារកិច្ចកំណត់ ភារកិច្ចបន្ថែម ភារកិច្ចថ្នាក់គួប និង ប្រាក់កំរៃ សំរាប់ការបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

រាជរដ្ឋាភិបាល

_បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២

_បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

_បានឃើញ ព្រះរាជក្រមលេខ ០២ ន.ស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

=

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦_៧_៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញ អនុក្រឹត្យលេខ ៣៨ អនក្រ បក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៦ ស្តីពីការបបម៉ោងកំណត់បន្ថែមនិងប្រាក់ម៉ោងបន្ថែម សំរាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សំរេច

មាត្រា១._ ក_<u>ភារកិច្ចកំណត់</u> : គឺការងារដែលកំណត់ជាទូទៅ អោយគ្រូបង្រៀនម្នាក់ទទួលខុសត្រូវគ្រប់ផ្នែកបង្រៀនសិស្សមួយថ្នាក់ក្នុងថេរវេលាមួយពេល នៃកាលវិភាគប្រចាំថ្ងៃនៅក្នុងគ្រឹះស្ថានសិក្សា គឺមួយថ្ងៃបង្រៀន ៥ ម៉ោងសិក្សា (មួយសប្តាហ៍បង្រៀន ២៥ម៉ោងសិក្សា) នៅពេលព្រឹក ឬនៅពេលរសៀល។ សំរាប់ថ្នាក់ទី៥ និងថ្នាក់ទី ៦ ភារកិច្ចកំណត់ក្នុងមួយថ្ងៃមាន ៥ម៉ោងកន្លះសិក្សា មួយសប្តាហ៍មាន ២៧ម៉ោង កន្លះសិក្សា។

ខ_<u>ភារកិច្ចបន្ថែម</u> : គឺការងារដែលបានប្រគល់បន្ថែមអោយគ្រូបង្រៀន មានភារកិច្ចកំណត់ម្នាក់ទទួលខុសត្រូវគ្រប់យ៉ាងក្នុងការបង្រៀនសិស្សមួយថ្នាក់ផ្សេងទៀត ក្នុងពេលផ្សេង តាមកាលវិភាគប្រចាំថ្ងៃនៅគ្រឹះស្ថានបឋមសិក្សា

គ_<u>ភារកិច្ចថ្នាក់គួប</u> : គឺការងារដែលប្រគល់អោយគ្រូបង្រៀនម្នាក់ទទួលខុសត្រូវគ្រប់យ៉ាងក្នុងការបង្រៀនសិស្សពីរក្រុម ឬ បីក្រុម ដែលមានកំរិតខុសៗគ្នា នៅក្នុងបន្ទប់រៀនតែមួយក្នុងថេរវេលាតែមួយ តាមកាលវិភាគទន់ភ្លន់ ដែលរៀបចំឡើងដោយគ្រូផ្ទាល់ និង បានឯកភាពពីនាយកសាលារៀន ព្រមទាំងមានការយល់ព្រមពីប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុក-ខ័ណ្ឌ ។

មាត្រា២._ មុខងាររបស់គ្រូ ដែលបំពេញភារកិច្ចបន្ថែម និងគ្រូថ្នាក់គួប :

ក_គ្រូដែលបំពេញភារកិច្ចបន្ថែម មានមុខងារធ្វើការរដ្ឋបាលគ្រប់យ៉ាងសំរាប់ថ្នាក់រៀន និងប្រើពេលបង្រៀនសិស្សតាមកាលវិភាគច្រើនជាង លើសគ្រូដែលបំពេញភារកិច្ចកំណត់ទូទៅ ដែលបង្រៀនតែមួយថ្នាក់ ។

ខ_គ្រូបង្រៀនថ្នាក់គួប មានមុខងារបំពេញការងាររដ្ឋបាលគ្រប់យ៉ាង សំរាប់ថ្នាក់រៀនច្រើនជាងតែប្រើពេលបង្រៀនតាមកាលវិភាគ ដូចគ្នានឹងគ្រូបំពេញភារកិច្ចកំណត់ទូទៅដែរ ។

មាត្រា៣._ អំពីប្រាក់ភារកិច្ចបន្ថែម :

ក_គ្រូបង្រៀនដែលត្រូវបានចាត់តាំងអោយបំពេញភារកិច្ចបន្ថែមក្នុងគ្រឹះស្ថានសិក្សាត្រូវ បានទទួលប្រាក់ភារកិច្ចបន្ថែម ស្មើនឹងប្រាក់បៀវត្សសរុបប្រចាំខែរបស់ខ្លួន ចាប់ពីពេលដែលបានចាប់ផ្តើមរហូតដល់ពេលដែលសាមី ជនបានបញ្ចប់ភារកិច្ច ។

ខ_គ្រូបង្រៀនដែលត្រូវបានចាត់តាំងអោយបំពេញភារកិច្ចនៅថ្នាក់គួបក្នុងគ្រឹះស្ថានបឋមសិក្សា ត្រូវបានទទួលប្រាក់ភារកិច្ចបន្ថែមដូចតទៅ ÷

- ស្មើនឹងចំនួនប្រាក់ ៦០% នៃប្រាក់បៀវត្សសរុបប្រចាំខែរបស់ខ្លួន ចំពោះថ្នាក់គួបដែលមានពីរកំរិត ចាប់ពីពេលដែលបានចាប់ផ្តើមរហូតដល់ពេលសាមីខ្លួនបានបញ្ចប់ភារកិច្ច ។
- ស្មើនឹងចំនួនទឹកប្រាក់ ៨០% នៃប្រាក់បៀវត្សសរុបប្រចាំខែរបស់ខ្លួន ចំពោះថ្នាក់គួប ដែលមានបីកំរិតចាប់ពីពេលដែលបានចាប់ផ្តើម រហូតដល់ពេលដែលសាមីខ្លួនបានបញ្ចប់ភារកិច្ច ។

មាត្រា៤.– ការចាត់តាំងគ្រូបង្រៀនអោយបំពេញភារកិច្ចបន្ថែម ឬ ភារកិច្ចថ្នាក់គួបត្រូវស្នើដោយនាយកសាលាបឋមសិក្សា ដោយមានការឯកភាពពីប្រធានការិយាល័យអប់រំ ស្រុក-ខ័ណ្ឌ និងមានការយល់ព្រមពីប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ។

មាត្រា៥.– បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៦.– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចកិច្ចរៀងៗខ្លួន ។

មាត្រា៧.– អនុក្រឹត្យនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យ លេខ ៧០ អនក្រ.បក

ស្ដីពីការបង្កើតគណៈកម្មាធិការជាតិអូឡាំពិក

សំរាប់ជនពិការកម្ពុជា

• • •

រាជរដ្ឋាភិបាល

– បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

– យោងតាមសំណើរបស់ អង្គការជនពិការកម្ពុជា

– ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

សម្រេច

មាត្រា១._បង្កើតគណៈកម្មាធិការជាតិអូឡាំពិកសំរាប់ជនពិការកម្ពុជា ដែលរួមមានសមាសភាព ÷

១_សម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី ២ ជាប្រធាន

២_ឯកឧត្តម **ស៊ុយ សែម** រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ជាអនុប្រធាន

៣_ឯកឧត្តម **គា សាវាន** រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា ជាសមាជិក

៤_ឯកឧត្តម **ម៉ម ប៊ុនហេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ជាសមាជិក

៥_ឯកឧត្តម **ប៊ុន អ៊ុយ** អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៦_លោក **ប្រធានអង្គការជនពិការកម្ពុជា** ជាសមាជិក

មាត្រា២._ គណៈកម្មាធិការជាតិអូឡាំពិក សំរាប់ជនពិការកម្ពុជា មានភារៈកិច្ចដឹកនាំការងារកីឡារបស់ជនពិការក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ រៀបចំលេខាធិការដ្ឋាន និងសហព័ន្ធកីឡានានារបស់ជនពិការ ទំនាក់ទំនងរកការជួយឧបត្ថម្ភពីអន្តរជាតិ ដើម្បីបំរើអោយវិស័យកីឡារបស់ជនពិការ ។

មាត្រា៣._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្ដាក្រសួងពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

អនុក្រឹត្យ លេខ ៧១ អនក្រ.បក
ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩៩៥.៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរប្រយុទ្ធប្រឆាំង គ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់អគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន

សំរេច

ជំពូក ១

បទបញ្ញត្តិទូទៅ

មាត្រា១.– អនុក្រឹត្យនេះកំណត់តួនាទី មុខងារសមត្ថកិច្ច និងរៀបចំអង្គភាពនានារបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ជំពូក ២

តួនាទី មុខងារ សមត្ថកិច្ច និងរចនាសម្ព័ន្ធ

មាត្រា២.– អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីដ៏សំខាន់ក្នុងការប្រមូលពត៌មាន និងក្នុងប្រតិបត្តិការប្រឆាំងនឹងការជួញដូរ ការផលិត និងការធ្វើជំនួញគ្រឿងញៀន និងសំរបសំរួលរាល់សកម្មភាពត្រួតពិនិត្យគ្រឿងញៀនរបស់ទីភ្នាក់ងារប្រតិបត្តិដទៃទៀត ដើម្បីធានាអោយបាននូវប្រសិទ្ធភាព និងសុវត្ថិភាព នៃការបង្ក្រាបគ្រឿងញៀននៅកម្ពុជា ។ នៅក្នុងតួនាទីនេះ អគ្គលេខាធិការដ្ឋានមានមុខងារសំខាន់ ៗ ដូចតទៅ :

១–រៀបចំជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងរាជរដ្ឋាភិបាលនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពបង្ក្រាបការជួញដូរ ការផលិត និងការជួញដូរគ្រឿងញៀន ដោយសំរបសំរួលអោយមានការចូលរួមជាសកម្មរបស់ក្រសួង និងអង្គការពាក់ព័ន្ធ ដទៃទៀត ។

២–តាមដានការអនុវត្តន៍នយោបាយ និងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៣–ជំរុញនិងសំរបសំរួលនូវវិធានការដែលចាត់ឡើងដោយក្រសួងពាក់ព័ន្ធ

៤–ទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលបរទេស និងអង្គការអន្តរជាតិនានា ក្នុងការប្រយុទ្ធ ប្រឆាំងគ្រឿងញៀន ។

មាត្រា៣ .– នៅក្នុងក្របខ័ណ្ឌនៃការបំពេញនូវតួនាទី និងមុខងាររបស់ខ្លួនខាងលើនេះ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវមានសមត្ថកិច្ចដូចតទៅ :

១–រៀបចំនិងចូលរួមក្នុងកិច្ចពិភាក្សារបស់អាជ្ញាធរជាតិប្រយុទ្ធ ប្រឆាំងគ្រឿងញៀន ។

២–តាក់តែងនូវពង្រាងច្បាប់ ក្រឹត្យអនុវត្ត និងបទបញ្ញត្តិក្នុងវិស័យបង្ការ និងបង្ក្រាបការជួញដូរ ការផលិត ការធ្វើជំនួញគ្រឿងញៀន និងការទាញផលចំណេញពីគ្រឿងញៀន ដោយសហការជាមួយនឹងក្រសួង និងអង្គការពាក់ព័ន្ធ ។

៣–ជំរុញ និងសំរបសំរួលការប្រមូលព័ត៌មាន និងស្ថិតិ ដែលកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិ និងការបញ្ជូនព័ត៌មាន និងស្ថិតិទាំងនោះទៅអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ។

៤–បញ្ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវអាសយដ្ឋានរបស់អាជ្ញាធរមានសត្ថកិច្ច ដើម្បីអនុវត្ត បទបញ្ញត្តិ នៃអនុសញ្ញា ។

៥–រៀបចំនីតិវិធី ស្តីពីសុវត្ថិភាព នៃការទុកដាក់ និងការកំទេចចោលគ្រឿងញៀន ដែលចាប់បាន ដោយសហការជាមួយក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

៦–ត្រួតពិនិត្យ និងបង្ក្រាបការជួញដូរ ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ការឆ្លងកាត់ ឬការស៊ុំចតគ្រឿងញៀន ឱសថ និងថ្នាំស្របច្បាប់ កំណត់ដោយក្រសួងសុខាភិបាល ដែលមានសារធាតុគ្រឿងញៀន ដោយសហការជាមួយនឹងក្រសួង និង អង្គការពាក់ព័ន្ធដទៃទៀត ។

៧–ដាក់អោយដំណើរការ នូវប្រព័ន្ធមួយសំរាប់ពិនិត្យតាមដាន និងវិភាគការប្រើប្រាស់គ្រឿងញៀន ដោយសហការជាមួយនឹងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

៨–រៀបចំ និងអនុវត្តកម្មវិធីអប់រំ បង្ការកុំអោយមានការប្រើប្រាស់គ្រឿងញៀន ដោយសហការជាមួយនឹងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

៩–សំរបសំរួលសកម្មភាពរបស់រដ្ឋាភិបាល ប្រឆាំងនឹងការសំអាតប្រាក់ទាក់ទងនឹង គ្រឿងញៀន ។

១០–សំរបសំរួលការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល លើសារធាតុសំរាប់ផ្សំគ្រឿងញៀន ។

១១-រៀបចំ និងអនុវត្តិនីតិវិធី និងកម្មវិធី សំរាប់ទទួលព្យាបាល និងជួយអ្នកញៀនអោយបានមករស់នៅក្នុងភាពធម្មតាវិញ ដោយសហការជាមួយនឹងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

មាត្រា៤.- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានរចនាសម្ព័ន្ធ ដូចតទៅ :

១-ខុទ្ទកាល័យអគ្គលេខាធិការ

២-អធិការដ្ឋាន

៣-មន្ទីរពិសោធន៍គ្រឿងញៀន

៤-នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

៥-នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល

៦-នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៧-នាយកដ្ឋានអនុវត្តច្បាប់

៨-នាយកដ្ឋាននីតិកម្មអប់រំ និងបង្ការការពារ

៩-នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យ

១០-អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ។ អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា៥.- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ដែលមានអគ្គលេខាធិការរងបីរូប ជាជំនួយការ ។ លើសពីនេះអគ្គលេខាធិការមានភារកិច្ចដឹកនាំ និងគ្រប់គ្រងដោយផ្ទាល់ អធិការដ្ឋាន មន្ទីរពិសោធន៍គ្រឿងញៀន និងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ។

អគ្គលេខាធិការរងម្នាក់ ត្រូវទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការអនុវត្តន៍ការងារនាយកដ្ឋានអនុវត្តច្បាប់ ។

អគ្គលេខាធិការរងម្នាក់ ត្រូវទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការអនុវត្តន៍ការងាររបស់នាយកដ្ឋានពីរ :

ក-នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល

ខ-នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

អគ្គលេខាធិការរងម្នាក់ទៀត ត្រូវទទួលបន្ទុកដឹកនាំ និង គ្រប់គ្រងការអនុវត្តន៍ការងាររបស់នាយកដ្ឋានពីរ ៖

ក–នាយកដ្ឋាននីតិកម្មអប់រំ និងបង្ការការពារ

ខ–នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យ

មាត្រា៦.– អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិធ្វើត្រាប្រើប្រាស់ តាមសេចក្តីត្រូវការរបស់ខ្លួន ។

អគ្គលេខាធិការមានសិទ្ធិធ្វើប្រកាសតែងតាំង ឬដកចេញពីតំណែងនូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិ ចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានចុះក្រោម ។

ជំពូក ៣

នាយកដ្ឋាន

មាត្រា ៧.– នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារៈកិច្ចដូចតទៅ ៖

ក–សំរបសំរួលផ្នែករដ្ឋបាល រាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ។

ខ–គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន។

គ–ធានាប្រសិទ្ធភាព និងសុវត្ថិភាពរដ្ឋបាល របស់អគ្គលេខាធិការដ្ឋាន ។

ឃ–សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន ។

ង–គ្រប់គ្រងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន

ច–លើក និងអនុវត្តគំរោងថវិកាប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន។

ឆ–ប្រមូលផ្តុំចំណូល និងចំណាយរបស់អគ្គលេខាធិការដ្ឋាន។

ជ–តាមដាន និងរើលើកការអនុវត្តន៍ថវិកា និងការគ្រប់គ្រងគណនី របស់អគ្គលេខាធិការដ្ឋាន ។

ឈ–ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយអោយបានសមស្រប ។

ញ–គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។

ង–ទទួល និងបែងចែកបរិក្ខារជូនដល់គ្រប់អង្គភាពនៅតាមកម្មវិធីចំណាយ ។

ច–រៀបចំ និងសម្រួលកិច្ចប្រជុំ និងការពិភាក្សាដេញដោលរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានជាជំនួយការ តាមការចាំបាច់ ។

មាត្រា ៨.– នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល មានភារកិច្ចដូចតទៅ

ក–រៀបចំយុទ្ធសាស្ត្រ និងលើកផែនទីកម្មវិធីគោលក្នុងការបង្ក្រាបការដាំដុះ ការផលិត និងការជួញដូរគ្រឿងញៀន ការនាំចេញ និងនាំចូលគ្រឿងញៀន និងក្នុងការលុបបំបាត់រាល់សកម្មភាពទាញផលចំណេញ ពីគ្រឿងញៀន ដោយសហការជាមួយក្រសួង និង អង្គការពាក់ព័ន្ធដទៃទៀត ។

ខ–រៀបចំគំរោងសកម្មភាព ដើម្បីអនុវត្តបទបញ្ញត្តិទាំងឡាយ នៃអនុសញ្ញាអន្តរជាតិ ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ឆ្នាំ ១៩៧១ និងឆ្នាំ ១៩៨៨ ។

គ–ពិនិត្យតាមដានការអនុវត្តន៍នយោបាយ និងសេចក្តីសំរេចរបស់អាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ឃ–រៀបចំ និងអនុវត្តនយោបាយមួយ ស្តីពីការបណ្តុះបណ្តាល មន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ ។

មាត្រា ៩ .– នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ :

ក–ទំនាក់ទំនងជាមួយនឹង រដ្ឋាភិបាលបរទេស និងអង្គការអនុតំបន់ និងអន្តរជាតិនានា ។

ខ–បញ្ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវអាសយដ្ឋានរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តបទបញ្ញត្តិ នៃអនុសញ្ញា ។

គ–បញ្ជូនពត៌មាន និង ស្ថិតិដែលកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិ ទៅអង្គការអន្តរជាតិ ដែលមានសមត្ថកិច្ច ។

ឃ–ចូលរួមក្នុងសកម្មភាពអនុតំបន់នានា ឬអន្តរជាតិ ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ ។

មាត្រា ១០.– នាយកដ្ឋានអនុវត្តច្បាប់ មានភារកិច្ចដូចតទៅ :

ក–ស៊ើបអង្កេតប្រមូលពតិមានពាក់ព័ន្ធនឹងគ្រឿងញៀន ដោយសហការជាមួយ នឹងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

ខ–ត្រួតពិនិត្យ និងបង្ក្រាបការដាំដុះ ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ការឆ្លងកាត់ ឬការស៊ុំចតគ្រឿងញៀន ឱសថ និងថ្នាំស្របច្បាប់ កំណត់ ដោយក្រសួងសុខាភិបាល ដែលមានសារធាតុគ្រឿងញៀន ដោយសហការជាមួយ នឹងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

គ–រៀបចំនិតិវិធី ស្ដីពីសុវត្ថិភាព នៃការទុកដាក់ និងការកំទេចចោលគ្រឿង ញៀន ដែលចាប់បាន ដោយសហការជាមួយក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត

ឃ–អនុវត្តច្បាប់គ្រឿងញៀន និងសាលក្រមតុលាការដែលពាក់ព័ន្ធនឹងគ្រឿង ញៀន ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និ[illegible] គ្រងដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានជាជំនួយការ តាមការចាំបាច់ ។

មាត្រា ១១ .–នាយកដ្ឋាននីតិកម្មអប់រំ និងបង្ការការពារមានភារៈកិច្ចដូចតទៅ :

ក–ជំនួយផ្លូវច្បាប់ សំរាប់សកម្មភាពទាំងអស់របស់អគ្គលេខាធិការដ្ឋាន។

ខ–តាក់តែងនូវពង្រាងច្បាប់ ក្រិត្យអនុវត្ត និងបទបញ្ញត្តិក្នុងវិស័យ បង្កា និងបង្ក្រាបការដាំដុះ ការផលិត ការធ្វើជំនួញគ្រឿងញៀន និងការទាញផល ចំណេញពីគ្រឿងញៀន ដោយសហការជាមួយនឹងក្រសួង និងអង្គការពាក់ព័ន្ធ ។

គ–សំរបសំរួល និង ចូលរួមក្នុងការបង្កើត និងអនុវត្តនូវកម្មវិធីប្រឆាំងនឹងការ សំអាតលុយ ។

ឃ–តាមដានការវិវត្តន៍ក្របខ័ណ្ឌនីតិក្រមរបស់រដ្ឋ និងលើកសំណើកែលំអ ច្បាប់ក្រឹត្យអនុវត្តនិងបទបញ្ញត្តិ ដែលពាក់ព័ន្ធ និង គ្រឿងញៀន ។

ង-រៀបចំ និងអនុវត្តកម្មវិធីអប់រំបង្ការ និងកាត់បន្ថយការប្រើប្រាស់គ្រឿងញៀននៅក្នុងប្រទេស ដោយសំរបសំរួល និងសហការអោយបានល្អ ជាមួយនឹងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

ច-ដាក់អោយដំណើរការ នូវប្រព័ន្ធមួយសំរាប់ពិនិត្យតាមដាន និងវិភាគការប្រើប្រាស់គ្រឿងញៀន ដោយសហការជាមួយនឹងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

ឆ-រៀបចំ និងអនុវត្តនីតិវិធី និងកម្មវិធី សំរាប់ទទួលព្យាបាល និងជួយអ្នកញៀនអោយបានមករស់នៅក្នុងភាពធម្មតាវិញ ដោយសហការជាមួយនឹងក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និងគ្រប់គ្រង ដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានជាជំនួយការ តាមការចាំបាច់ ។

មាត្រា ១២.- នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យមានភារកិច្ចដូចតទៅ :

ក-សំរបសំរួល និងចូលរួមកិច្ចប្រតិបត្តិការជាមួយក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ក្នុងការពិនិត្យតាមដានការត្រួតពិនិត្យលើឱសថ និង ថ្នាំស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ។

ខ-សំរបសំរួល ការបង្កើតឡើង និងការអនុវត្តន៍នូវការត្រួតពិនិត្យសារធាតុសំរាប់ផ្សំគ្រឿងញៀន ។

នាយកដ្ឋាន ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ ។

ជំពូក ៤

ខុទ្ទកាល័យអគ្គលេខាធិការ

មាត្រា១៣ .- ខុទ្ទកាល័យនៃអគ្គលេខាធិការ ត្រូវបានដឹកនាំដោយនាយខុទ្ទកាល័យមួយរូប និងមាននាយរងខុទ្ទកាល័យមួយចំនួន ជាជំនួយការតាមការចាំបាច់ ។ ខុទ្ទកាល័យនៃអគ្គលេខាធិការ ត្រូវទទួលបន្ទុកការងារទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន ។

ជំពូក ៥

មន្ទីរពិសោធន៍គ្រឿងញៀន

មាត្រា១៤.– មន្ទីរពិសោធន៍គ្រឿងញៀន ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ មានភារកិច្ចធ្វើការស្រាវជ្រាវគ្រឿងញៀន និងធ្វើតេស្តថ្នាំ ដោយមានសហការជាមួយនឹងមន្ទីរពិសោធន៍របស់ក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត ។ មន្ទីរពិសោធន៍គ្រឿងញៀន មានសិទ្ធិលើកសំណើ ស្តីពីការហាមឃាត់ការផលិត និងការធ្វើជំនួញឱសថ និងថ្នាំស្របច្បាប់ កំណត់ដោយក្រសួងសុខាភិបាល ដែលមន្ទីរពិសោធន៍គ្រឿងញៀន ស្រាវជ្រាវរកឃើញថាមានសារធាតុគ្រឿងញៀន លើសពីកំរិតដែលបានអនុញ្ញាត្តិ ។

ជំពូក ៦

អធិការដ្ឋាន

មាត្រា១៥.– អធិការដ្ឋាន ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអធិការមួយរូប និងមានអធិការរងជាជំនួយការតាមការចាំបាច់ អធិការដ្ឋានមានភារកិច្ចដូចតទៅ :

ក–ធ្វើអធិការកិច្ចទៅលើគ្រប់អង្គភាព ក្រោមឱវាទរបស់ អគ្គលេខាធិការដ្ឋាន

ខ–ធ្វើរបាយការណ៍ជូនអគ្គលេខាធិការ ស្តីពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចរួចហើយនោះ និងពីមធ្យោបាយកែលំអ នៃការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។

គ–ប្រតិបត្តិភារកិច្ច ដែលអគ្គលេខាធិការបានប្រគល់ទុកចិត្តអោយធ្វើ ។

ជំពូក ៧

អង្គភាពមូលដ្ឋានក្រោមឱវាទ

មាត្រា១៦.– អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានការិយាល័យបង្ក្រាបគ្រឿងញៀន នៅតាមខេត្ត–ក្រុង តាមការចាំបាច់ ដើម្បីអនុវត្តការងារ ដែលអគ្គលេខាធិការដ្ឋានប្រគល់អោយ ។

មាត្រា១៧._នៅពេលអគ្គលេខាធិការដ្ឋានបានដំណើរការ មន្ទីរ និងការិយាល័យខេត្ត_ក្រុង ប្រឆាំងគ្រឿងញៀនទាំងអស់ ត្រូវធ្វើសមាហរណកម្មទៅក្នុងអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ជំពូក ៨

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា១៨._អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមលក្ខខណ្ឌ នៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង ឬស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

ជំពូក ៩

អវសានប្បញ្ញត្តិ

មាត្រា១៩._បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា២០._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ **នាយករដ្ឋមន្ត្រីទី២**

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

ឧបសម្ព័ន្ធ

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន
នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន



អនុក្រឹត្យ លេខ ៧២ អនក្រ.បក
ស្តីពីការបង្កើតក្រុមហ៊ុនចំការកៅស៊ូ ពាមជាំង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស.រកត ០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីការដាក់អគ្គនាយកដ្ឋានចំការកៅស៊ូ អោយស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សំរេច

មាត្រា១.– ត្រូវបានបង្កើតក្រុមហ៊ុនចំការកៅស៊ូពាមជាំង មានថ្នាក់ស្មើនាយកដ្ឋាន ស្ថិតនៅក្រោមអាណាព្យាបាលរបស់អគ្គនាយកដ្ឋានចំការកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ ដោយកាត់យកភូមិសាស្ត្រ មូលដ្ឋានចំការកៅស៊ូពាមជាំង នៃក្រុមហ៊ុនចំការកៅស៊ូជប់ ទៅតាមផែនទីភ្ជាប់ជាមួយអនុក្រឹត្យនេះ ។

មាត្រា២.- ក្រុមហ៊ុនចំការស៊ូពាមជាំង ជាអង្គភាពសាធារណៈ ប្រភេទក្រុមហ៊ុនរដ្ឋ ត្រូវបានអនុវត្តតាមបទបញ្ញត្តិ នៃលក្ខន្តិកៈទូទៅរបស់សហគ្រាសសាធារណៈ ។

មាត្រា ៣.- ក្រុមហ៊ុនចំការកៅស៊ូពាមជាំង មានមុខងារ និងភារៈកិច្ចដូចខាងក្រោម :

–កសាងផែនការកម្មវិធីអភិវឌ្ឍន៍ដំណាំកៅស៊ូ ដោយប្រើប្រាស់ដំណាំកៅស៊ូដែលមានស្រាប់ និងដាំដុះថ្មី ។

–ដឹកនាំនិងសំរេចរាល់សកម្មភាពផលិតកម្មអាជីវកម្ម ដំណាំកៅស៊ូរបស់ក្រុមហ៊ុន សំដៅជំរុញអភិវឌ្ឍន៍ បង្កើនទិន្នផលទាំងបរិមាណ និងគុណភាពកៅស៊ូ ។

–ចូលរួមសកម្មភាពក្នុងការជំរុញផ្នែកវិទ្យាសាស្ត្រ បច្ចេកទេសដំណាំកៅស៊ូ ។

–ដឹកនាំ និង គ្រប់គ្រងខ្សែសង្វាក់គ្រឿងចក្រផលិតកម្មជឿនលឿន និងរោងចក្រកែច្នៃជ័រកៅស៊ូ ដើម្បីធានាគុណភាព និងទិន្នផលខ្ពស់ ។

– កសាងប្រព័ន្ធបៀវត្សអោយបានសមស្របតាមសភាពការណ៍សេដ្ឋកិច្ចទីផ្សារ លើកកំពស់ជីវភាពរស់នៅ វប្បធម៌ អប់រំ ថែបំប៉នសុខភាព សន្តិសុខ ជូនមន្ត្រីបុគ្គលិក កម្មករ បំរើការងារក្នុងក្រុមហ៊ុន និងបន្ទុកគ្រួសាររបស់គេអោយមានស្មេរភាពត្រឹមត្រូវល្អ ។

មាត្រា ៤.- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានចំការកៅស៊ូ ត្រូវកំណត់ និងបែងចែកចលនៈ អចលនៈទ្រព្យ និងកំលាំងពលកម្ម ដែលពាក់ព័ន្ធ ចេញពីក្រុមហ៊ុនចំការកៅស៊ូជប់ ប្រគល់ជូនក្រុមហ៊ុនចំការកៅស៊ូពាមជាំង ដើម្បីដំណើរការផលិតកម្ម និងអាជីវកម្ម ។

មាត្រា៥.- ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គភាពចំណុះក្រុមហ៊ុននេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា៦.- ក្រុមហ៊ុនចំការស៊ូពាមជាំង ដឹកនាំដោយនាយកក្រុមហ៊ុនមួយរូប និងនាយករងមួយចំនួនជាជំនួយការ ។

មាត្រា ៧.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

អនុក្រឹត្យ លេខ: ២១០ អនក្រ.តត

ស្ដីពីការផ្ទេរការកិច្ចនាយកដ្ឋានគតរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១.– ត្រូវបានផ្ទេរភារកិច្ច :

១–លោកឧត្តមសេនីយ៍ត្រី **វ័ន្ធ ម៉ែន** ពីប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹត្យការ អោយមកទទួលជាទីប្រឹក្សា ឯកឧត្តម **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

២–លោកឧត្តមសេនីយ៍ត្រី **ហេង ម៉ារក់** ពីប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម អោយមកទទួលជាប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ ។

៣–លោកឧត្តមសេនីយ៍ត្រី **ឈូ វ៉ាមីន** ពីទីប្រឹក្សាឯកឧត្តម **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អោយមកទទួលជាប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម ។

មាត្រា២.– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង និងស្ថាប័នពាក់ព័ន្ធ និងអស់លោកដែលមានឈ្មោះដូចក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី២**
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
អ៊ឹង ហួត	**ហ៊ុន សែន**

២_សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ តុលា ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ: ៤២ សសរ

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម **ជា ចាន់តូ** រដ្ឋមន្ត្រីក្រសួងផែនការ ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **ចម ប្រសិទ្ធ** ដែលត្រូវអញ្ជើញទៅព្យាបាលជម្ងឺនៅប្រទេសថៃ ចាប់ពីថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៧ រហូតដល់ពេលឯកឧត្តម **ចម ប្រសិទ្ធ** វិលត្រឡប់មកវិញ ។

ប្រការ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាននិងឯកឧត្តម **ជា ចាន់តូ** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ុង ហួត ហ៊ុន សែន

II-ការងាររបស់ក្រសួង

១_ទីស្តីការគណៈរដ្ឋមន្ត្រី

៣_ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ តុលា ឆ្នាំ ១៩៩៧

ប្រកាស លេខ: ១៥១ ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការដូចមានឈ្មោះខាងក្រោម :

១-កញ្ញា **សម សុគន្ធា** ជាជំនួយការឯកឧត្តម **ឈាន់ ផាន់** អគ្គលេខាធិការរាជរដ្ឋាភិបាល មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ក្នុងពេលបំពេញការងារ ។

២-លោក **ម៉ៅ ច័ន្ទរស្មី** ជាលេខាធិការឯកឧត្តម **ឈាន់ ផាន់** អគ្គលេខាធិការរាជរដ្ឋាភិបាល មានឋានៈស្មើប្រធានការិយាល័យ ក្នុងពេលបំពេញការងារ

ប្រការ ២ : ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញកិច្ច ព្រមទាំងសាម៉ីខ្លួន ត្រូវទទួលបន្ទុកអនុវត្តន៍ប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
សុខ អាន

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ តុលា ឆ្នាំ ១៩៩៧

ប្រកាស លេខ: ១៥១ ប្រក (ស្ទន)

ស្តីពីការតែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រធាននាយកដ្ឋានឧស្សាហកម្មរ៉ែ និងសំណង់

សំរេច

ប្រការ ១ : តែងតាំង ÷

១-លោក **ឈុន ម៉ាន** ជាប្រធានការិយាល័យកិច្ចការឧស្សាហកម្ម-សិប្បកម្ម និងទឹកស្អាត នៃនាយកដ្ឋានឧស្សាកម្មរ៉ែ ថាមពល របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានឧស្សាហកម្ម រ៉ែ និងសំណង់ នាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញកិច្ច និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តសេចក្តីប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

សុខ អាន

* * *

២_ធនាគារជាតិនៃកម្ពុជា

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ តុលា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៧៩៦.១៥៣ ប្រក

ស្តីពីអាជ្ញាប័ណ្ណរបស់ធនាគារដែលបង្កើតឡើង

ក្រោមទំរង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុក

* * * *

ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ពិសេសលើមាត្រា ៤_៧_៣៣_៣៨ និង ៦១
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩២ ស្តីពីការគ្រប់គ្រងធនាគារពាណិជ្ជកម្ម ពិសេសលើមាត្រា ៣_១៤_១៦_៤_១៨_២២_២៥ និង ២៧
- បានឃើញបទបញ្ជាលេខ ធ ៧៩៥_០៣ ស្តីពីអនុបាតបង្ការហានិភ័យ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ១៩៩៥
- បានឃើញសារាចរលេខ ធ៧៩៥_០៣ ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៥ ស្តីពី អនុបាត បង្ការហានិភ័យ
- តាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ និងខុទ្ទកាល័យនៃធនាគារជាតិ

សំរេច

ក្នុងឋានៈជាអាជ្ញាធរអាណាព្យាបាលនៃប្រព័ន្ធធនាគារ និងដោយសំអាងលើអំណាចនៃការចេញបទបញ្ញារបស់ខ្លួន ធនាគារជាតិនៃកម្ពុជាសូមកំណត់បណ្តាលក្ខខ័ណ្ឌសំខាន់ៗដូចតទៅ ដែលបណ្តាក្រុមហ៊ុនពាណិជ្ជកម្មនៃច្បាប់ក្នុងស្រុកត្រូវគោរពតាម ដើម្បីដាក់មកធនាគារជាតិ ឬមួយនូវសំណើសុំអាជ្ញាប័ណ្ណ ដើម្បីអាចធ្វើសកម្មភាពធនាគារ ឬមួយនូវសំណើសុំបន្តអាជ្ញាប័ណ្ណឡើងវិញ ប្រសិនបើអាជ្ញាប័ណ្ណនេះត្រូវបានអនុញ្ញាតអោយសំរាប់រយៈពេលមានកំណត់ ។

ទោះបីរយៈពេលកំណត់ត្រូវបានអនុញ្ញាតអោយត្រឹមណាក្តី អាជ្ញាប័ណ្ណជានិច្ចកាលអាចត្រូវទុកជាមោឃៈវិញបាន ។

ល័ក្ខខ័ណ្ឌនៃការចេញ ឬការបន្តឡើងវិញនៃអាជ្ញាប័ណ្ណដែលពាក់ព័ន្ធនឹងសាខាធនាគារបរទេស នឹងត្រូវជូនដំណឹងដល់បណ្តូធនាគារសាមីតាមប្រកាស នៅពេលក្រោយ ។

ប្រការ១ : ធនាគារដែលកំពុងផ្តើមបង្កើតត្រូវដឹងថា គ្មានអាជ្ញាប័ណ្ណណានឹងត្រូវចេញអោយឡើយ ទោះក្នុងពេលយូរយ៉ាងណាក្តី ដរាបណារាល់លក្ខខ័ណ្ឌដែលចែងនៅបណ្តាប្រការខាងក្រោមនេះ ពុំត្រូវបានគោរពតាមទាំងស្រុងទេនោះ ។

ប្រការ២ :ក្នុងគំរោងដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណរបស់ខ្លួន ធនាគារកំពុងធ្វើសកម្មភាពដែលអាជ្ញាប័ណ្ណមានរយៈពេលកំណត់ ត្រូវតែអនុលោមតាមរាល់លក្ខខ័ណ្ឌនៃការស្នើសុំអាជ្ញាប័ណ្ណ និងជាអាទិ៍តាមលក្ខខ័ណ្ឌដែលពាក់ព័ន្ធនឹងសមាសភាព និងការទទួលខុសត្រូវរបស់ភាគទុនិក ចាប់តាំងពីពេលនេះ ឬយ៉ាងយឺតបំផុតក្នុងពេលដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណឡើងវិញ។

អំពីសកម្មភាពធនាគារ

ប្រការ៣ : ប្រតិបត្តិការដែលផ្តុំបង្កើតសកម្មភាពធនាគាររួមមាន ÷

១_ការផ្តល់ឥណទានគ្រប់ប្រភេទ ចំពោះសាធារណជនដោយមានកំរៃ ។

២_ការទទួលពីសាធារណជននៃប្រាក់បញ្ញើមិនមានសញ្ញាប្រើប្រាស់ ។

៣_ការដាក់អោយអតិថិជនចាត់ចែងនិងប្រព្រឹត្តិកម្មនៃមធ្យោបាយទូទាត់ជារូបិយវត្ថុជាតិ ឬជារូបិយប័ណ្ណ ។

ប្រការ៤ : អង្គភាពណាដែលអនុវត្តជាប្រក្រតី នូវប្រតិបត្តិការណាមួយក្នុងចំណោមប្រតិបត្តិការទាំង៣ ប្រភេទខាងលើ ត្រូវបានចាត់ទុកយ៉ាងគ្រប់គ្រាន់ថា បានធ្វើអាជីវកម្ម ធនាគារ

ដោយពិត។ ដូច្នេះអង្គភាពនោះត្រូវឋិតក្នុងកាតព្វកិច្ចប្រតិបត្តិតាមលក្ខខ័ណ្ឌនានា នៃការផ្ដល់អាជ្ញាប័ណ្ណ ។

ប្រការ៥ : ធនាគារអាចអនុវត្តដោយផ្ទាល់ ឬដោយប្រយោល (តាមរយៈបុគ្គលសម្ព័ន្ធ) សំរាប់ខ្លួនឯងផ្ទាល់ ឬជួសអោយអតិថិជនរបស់ខ្លួន នូវសកម្មភាពហិរញ្ញវត្ថុខ្លះទៀត ជាអាទិ៍ គឺប្រតិបត្តិការលើមូលបត្រ និងលើមាសឬលោហធាតុមានតំលៃលើកលែងតែការជានារ៉ាប់រង ។

អំពីនីតិវិធីនៃការចេញអាជ្ញាប័ណ្ណ

ប្រការ៦ : ដោយឧបត្តិហេតុប៉ះលើការបង្កើតរូបិយវត្ថុ (La création monétaire) និងលើហានិភ័យដែលអាចកើតមានចំពោះអ្នកផ្ញើប្រាក់ ឬចំពោះឥណទាយក សកម្មភាពធនាគារអាច ប្រព្រឹត្តិបានតែដោយអង្គភាពដែលបានទទួលប្រតិស្រុតណិពិសេសពីធនាគារជាតិនៃ កម្ពុជា ជាអាជ្ញាធរអាណាព្យាបាលនៃប្រព័ន្ធធនាគារ និងដែលបង្កើតឡើងក្រោមទំរង់ជាក្រុមហ៊ុន មូលធននៃច្បាប់ក្នុងស្រុក ឬជាសាខារបស់ធនាគារបរទេស ។

ប្រការ៧ : សេចក្ដីយល់ព្រមបណ្ដោះអាសន្ន និងមានលក្ខខ័ណ្ឌត្រូវធនាគារជាតិ នៃកម្ពុជា ផ្ដល់អោយជាលាយលក្ខ័អក្សរទៅម្ចាស់សំណើរ បន្ទាប់ពីបានសិក្សាលើគោលចំបងៗ នៃគំរោង និងនៃសមាសភាពដើមទុន ។

ប្រការ៨ : អាជ្ញាប័ណ្ណអាចចេញអោយជាផ្លូវការបាន តែក្រោយពីការបានបំពេញត្រឹមត្រូវលើរាល់លក្ខខ័ណ្ឌ និងបែបបទនានា ដោយគិតទាំងការបង់សោហ៊ុយបើកសំណុំលិខិត និងកំរៃអាជ្ញាប័ណ្ណផង ។

ប្រការ៩ : អាជ្ញាប័ណ្ណត្រូវបានចេញអោយ ឬមួយសំរាប់រយៈពេលគ្មានកំណត់ ឬមួយសំរាប់រយៈពេលមានកំណត់ ។ ប្រសិនបើអាជ្ញាប័ណ្ណបានត្រូវអនុញ្ញាតអោយដោយរយៈពេលមានកំណត់ ពាក្យស្នើសុំបន្តឡើងវិញត្រូវផ្ញើទៅធនាគារជាតិនៃកម្ពុជា យ៉ាងយឺតបំផុត ៦ខែ មុន ផុតកំណត់សុពលភាពនៃអាជ្ញាប័ណ្ណកំពុងប្រើ ។

អំពីលក្ខខណ្ឌនិងបែបបទតម្រូវអោយបំពេញ
ដែលពាក់ព័ន្ធនឹងសមាសភាពភាគទុនិករបស់
ក្រុមហ៊ុននៃច្បាប់ក្នុងស្រុក និងភាពច្រាកដប្រជានៃសំណុំឯកសារសំរាប់ផ្តល់អាជ្ញាប័ណ្ណ
សមាសភាពនៃភាគទុនិក (អត្តសញ្ញាណ និង ស្ថានភាពហិរញ្ញវត្ថុ)

ប្រការ១០ : បញ្ជីរាយនាមភាគទុនិក ដែលមានភាគហ៊ុនចាប់តាំងពីប្រាំភាគរយ(៥%)ឡើងទៅ ត្រូវ តែមានផ្តល់មកធនាគារជាតិនៃកម្ពុជា ។

ប្រការ១១ : នៅក្រោមកំពស់ខាងលើនេះ ធនាគារជាតិនៃកម្ពុជាចាត់ទុកជាអាទិកាលថា ភាគទុនិកទាំងនេះជាអ្នកចាត់ចែងប្រាក់សន្សំរបស់ខ្លួនដើម្បីកំរៃ គឺពុំមែនដើម្បីប្រមូលចំណែកក្នុងការគ្រប់គ្រងធនាគារឡើយ ។ ចាប់ពីកំពស់នេះឡើងទៅអាជ្ញាធរអាណាព្យាបាល ត្រូវប្រមូលពតិមាន ទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិកទាំងនោះ ។

ប្រការ១២ : រាល់ភាគទុនិក ដែលមានក្នុងបញ្ជីរាយនាមបែបនេះ ត្រូវប្រកាសជាលាយលក្ខអក្សរថាខ្លួនចូលហ៊ុននោះ គឺពិតជាសំរាប់ខ្លួនឯងផ្ទាល់ ។

ប្រការ១៣ : ក្នុងករណីដែលភាគទុនិករបស់ធនាគារកំពុងផ្តើមបង្កើត ឬធនាគារកំពុងមានសកម្មភាពខ្លួនឯងជាក្រុមហ៊ុនមួយដែរ ÷

១_សំណុំលិខិតសុំអាជ្ញប័ណ្ណ ត្រូវមានបញ្ជីរាយនាមភាគទុនិកធំៗរបស់ក្រុមហ៊ុននោះ ប្រសិនបើភាគហ៊ុនរបស់គេមានកំពស់ស្មើ ឬលើសពី ៥% នៃដើមទុនរបស់ធនាគារដែលកំពុងផ្តើមបង្កើត ឬដែលមានសកម្មភាពហើយនោះ ។

២_ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុនជាភាគទុនិកនេះ ត្រូវមានអាស័យដ្ឋានបិតនៅទីតាំងហិរញ្ញវត្ថុ មានច្បាប់ទម្លាប់ត្រឹមត្រូវ ហើយដែលត្រូវបានទទួលស្គាល់ថាដូច្នោះមែន ពីសំណាក់ធនាគារជាតិនៃកម្ពុជា ។

៣–ការដាក់ហ៊ុនមានលក្ខណៈបន្តគ្នាជាល្បាក់ (en cascade) មិនត្រូវបានអនុញ្ញាតអោយធ្វើឡើយ លើកលែងតែមានការអនុញ្ញាតពិសេស ពីធនាគារកណ្តាលក្រោយពេលបានសិក្សាស៊ីជម្រៅ ។

ប្រការ១៤ : នៅក្នុងសមាសភាពទុនិករបស់ធនាគារកំពុងផ្តើមបង្កើតឬកំពុងមានសកម្មភាព ត្រូវតែមានជាដាច់ខាតនូវ

–ឬមួយភាគនិកមួយរូបដែលកាន់កាប់ហ៊ុនភាគច្រើននៃដើមទុន ឬ នៃសិទ្ធិបោះឆ្នោត

–ឬមួយភាគនិកច្រើនរូប ដែលម្នាក់ៗមានភាគហ៊ុនកំពស់ណាមួយដែលមានឥទ្ធិពលលើការគ្រប់គ្រងធនាគារ ។

ប្រការ១៥ : រាល់ភាគទុនិកដែលមានភាគហ៊ុនដោយផ្ទាល់ ឬ ដោយប្រយោលយ៉ាងតិចស្មើ ២០% នៃទុនឬនៃសិទ្ធិបោះឆ្នោតត្រូវបានចាត់ទុកជាស្វ័យប្រវត្តិ ដោយធនានាគារជាតិថាភាគទុនិកឥទ្ធិពល ។

ប្រការ១៦ : រាល់ភាគទុនិកដែលមានហ៊ុនភាគច្រើន ឬមានឥទ្ធិពល ត្រូវបានទទួលស្គាល់ថាស្ថានភាពហិរញ្ញវត្ថុផ្ទាល់របស់ខ្លួនមានលទ្ធភាពពិតប្រាកដក្នុងការស្តារឡើង ដោយរួមជាមួយភាគទុនិកមានឥទ្ធពល ដទៃទៀត ឬមួយដោយឯកឯង ឬមួយដោយមានបញ្ជាពីអាជ្ញាធរអាណាព្យាបាល នូវស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នៅពេលជួបប្រទះខិនភាព ។

ក្នុងករណីពលក្ខារ(ឬអភិទ្រោះ)សាធនភាពរបស់ធនាគារ ហើយសំដៅការពារប្រាក់បញ្ញើរបស់អតិថិតា អាជ្ញាធរអាណាព្យាបាលត្រូវហៅរកភាគទុនិកកាន់កាប់ហ៊ុនភាគច្រើន ឬមានឥទ្ធិពលដែល ជាអ្នកទទួលខុ... ដោយផ្ទាល់ ឬ ដោយប្រយោលក្នុងការគ្រប់គ្រងធនាគារ ដើម្បីបង្ខំអ្នកទាំងនោះអោយបញ្ចាធនាគារ អោយ គោរពបទបញ្ញត្តិប្រុងប្រយ័ត្នពាក់ព័ន្ធនឹងសាធនភាពដែលជារួមមាន :

១–កំពស់ដើមទុនអប្បបរមា និងការបង្ហាញអោយឃើញជាអចិន្ត្រៃយ៍ នៃដើមទុននោះ នៅខាងទ្រព្យសកម្មតាមតំលៃពិត ធ្វើយ៉ាងណាអោយទ្រព្យសកម្មពិតក្រោយពីដកចេញនូវខ្ទង់ទ្រព្យគ្មានតំលៃ មានតំលៃលើសជាអចិន្ត្រៃយ៍ពីបំណុលត្រូវសងតតិយជន ក្នុងកំរិតយ៉ាងតិច ក៏ស្មើនឹងដើមទុនអប្បបរមាដែរ ។

២_និងអនុបាត ស្តីពីហានិភ័យអនុលោមតាមបទប...លេខ ធ៧៩៥_០៣ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ១៩៩៥ និង សារាចរលេខ ៧៩៥_០៣ ចុះថ្ងៃទី២៧_៥_១៩៩៥ ។

ប្រការ១៧ :ក្នុងការអនុវត្តន៍ កាលបើមិនអាចបន្ថយហានិភ័យបានទេ ភាគទុនិកដែលមានភាគហ៊ុនច្រើន ឬ មានឥទ្ធិពលទាំងនេះត្រូវជាប់កាតព្វ...បំពេញបន្ថែមនូវមូលនីធិផ្ទាល់

ឬទុនអចិន្ត្រៃយ៍ ដទៃទៀតដូចជាការខ្ចីប្រាក់ជាប់លក្ខខ័ណ្ឌជាដើម សំដៅជៀសវាង ពលក្ការក្ស័យធន ក្រោមទណ្ឌកម្មធនាគារជាតិដាក់ធនាគារនោះអោយនៅក្រោមការ អភិបាលបណ្តោះអាសន្ន ដោយអនុលោមតាមមាត្រា ២២ នៃអនុក្រឹត្យដែលបាន ពោលពីខាងដើមនេះស្រាប់ ។

ប្រការ១៨ :ភាគទុនដែលមមានភាគហ៊ុនច្រើន ឬមានឥទ្ធិពលត្រូវទទួលស្គាល់ជាលាយល័ក្ខ អក្សរ ថា គេបានយល់ដឹងពីកាតព្វកិច្ចទាំងឡាយ ដែលផ្តើមចេញពីនាទីរបស់គេជាភាគ ទុនិកមានភាគ ហ៊ុនច្រើន ឬមានឥទ្ធិពលនោះ ដោយរាប់បញ្ចូលទាំងធនាគារក្នុងស្រុក ជាបុត្តសម្ព័ន្ធ នៃធនាគារមានទីស្នាក់ការកណ្តាលនៅក្រៅប្រទេស ។

ប្រការ១៩ :សមត្ថភាពហិរញ្ញវត្ថុរាល់ភាគទុនិកដែលមានភាគហ៊ុនច្រើន ឬមានឥទ្ធិពលត្រូវបាន វាយតំលៃដោយធនាគារជាតិ តាមរយៈពតិមានដូចខាងក្រោម ÷

១_រូបវន្តបុគ្គលត្រូវបង្ហាញលិខិតសំអាងធនាគារ និងពន្ធដារអំពីកំពស់ និងស្ថេរ ភាពនៃប្រតិលាភនៃភោគទ្រព្យផ្ទាល់ខ្លួនដែលជាអាទិ៍តំណាងដោយអចលនវត្ថុ និង អំពីស្ថានភាពពាណិជ្ជកម្មរបស់ពួកគេ ។

២_ក្រុមហ៊ុនត្រូវបង្ហាញភស្តុតាងពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ដោយបង្ហាញ តារាងតុល្យការ និងគណនីអាជីវកម្មមានវិញ្ញាបនកម្ម ប្រចាំ ៣ ការិយបរិច្ឆេទ ចុង ក្រោយ ផ្អែកលើទិន្នន័យខាងធនាគារ និងខាងពន្ធដារពាក់ព័ន្ធ ។

៣_ភាគទុនិកមានភាគហ៊ុនច្រើន ឬមានឥទ្ធិពលរបស់ក្រុមហ៊ុនដែលជាភាគ ទុនិកក៏ត្រូវបង្ហាញភស្តុតាងអំពីសមត្ថភាពហិរញ្ញវត្ថុរបស់ខ្លួន តាមរបៀបដូចគ្នានេះ ដែរ ។

ប្រការ២០ : ភាគទុនិកដែលមានភាគហ៊ុនច្រើន ឬមានឥទ្ធិពលរងកាតព្វកិច្ចជាចាំបាច់ក្នុងការធ្វើ អោយមានការគោរពតាមបទបញ្ញត្តិពាក់ព័ន្ធនឹងសាធនភាពល្មមមាន ÷

១_ការបំបែកហានិភ័យ ដោយអនុលោមតាមមាត្រា ១៤ និង ១៨ នៃអនុក្រឹត្យ លេខ ២៩ អនក្រ ចុះថ្ងៃទី ១៦_១១_១៩៩២

២_ការគិតនៃភាគ្យកម្ម តាមស្មារតីមាត្រា ១៦ នៃអនុក្រិត្យលេខ ២៩ អនក្រ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩២ ។

៣_និងការកាត់ដកក្នុងការគិតគួរកម្ពុលនិធិផ្ទាល់សុទ្ធ នូវការផ្តល់ជំនួយដល់សម្ព័ន្ធភាគី (Related Parties) ទោះក្រោមរូបភាពណាក៏ដោយ ដោយអនុលោមតាមបទបញ្ជាលេខ ធ ៧៩៥_០៣ ចុះថ្ងៃទី ២២_០៥_១៩៩៥ និងសារាចរលេខ ធ៧៩៥_០៣ ចុះថ្ងៃទី ២៧_០៥_១៩៩៥ ។

ក្នុងការគណនារកអនុបាតដែលលើកឡើងនៅកំណុ១ និង២ នៃប្រការនេះ ធនាគារកណ្តាលអាចយកមកត្រិះរិះផងដែរ តាមសំណើមានមូលហេតុសុំអោយមានបដិបញ្ញត្តិ នូវមូលនិធិផ្ទាល់សុទ្ធរបស់ទីស្នាក់ការកណ្តាល ប្រសិនបើធនាគារក្នុងស្រុកខ្លួនឯងជាបុត្តសម្ព័ន្ធនៃធនាគារដែលមានទីស្នាក់ការកណ្តាលនៅកម្ពុជា ឬ ក្រៅប្រទេស ។ លក្ខខណ្ឌនានា ដែលជាបច្ច័យនាំអោយធនាគារជាតិនៃកម្ពុជាផ្តល់បដិប្បញ្ញត្តិអោយត្រូវបានអធិប្បាយនៅក្នុងចម្លើយរបស់ខ្លួន ចំពោះពាក្យសុំដ៏មានមូលហេតុ ដែលគេបានដាក់ស្នើមកនោះ ។

អំពីដើមទុនអប្បបរមា

ប្រការ២១ : ដើមទុនត្រូវបានកំរិតចំនួន ១០.០០០ លានរៀល ជាអប្បបរមាដោយមាត្រា ៣ នៃអនុក្រឹត្យលេខ២៩ អនក្រ ចុះថ្ងៃទី ១៦ ១១_១៩៩២ ស្តីពីការគ្រប់គ្រងធនាគារពាណិជ្ជកម្ម អាចត្រូវបានយកមកពិនិត្យឡើងវិញបាន ។

ប្រការ២២ : ដើមទុនអប្បបរមាដែលត្រូវបានកំរិតត្រូវប្រកាសជារូបិយវត្ថុជាតិ ហើយត្រូវបង់ជំរះទាំងស្រុង 100% មុនពេលទទួលអាជ្ញាប័ណ្ណ តាមរយៈការបង់ប្រាក់ចូលគណនីពិសេសបើកសំរាប់ធនាគារកំពុងផ្តើមបង្កើតនោះនៅធនាគារជាតិនៃកម្ពុជា ។

ប្រការ២៣ : ប្រសិនបើការបង់ប្រាក់ហ៊ុនបានទទួលជារូបិយប័ណ្ណអំពីភាគទុនិក ធនាគារជាតិនៃកម្ពុជា អាចទាមទារអោយលក់អោយខ្លួននូវរូបិយប័ណ្ណនោះជាមុន ទល់នឹងប្រាក់រៀល

ប្រការ២៤ : មូលនិធិដែលបានបង់ចូល ដោយមានយុត្តិការជាសំអាង នឹងត្រូវប្រគល់អោយធនាគារ បង្កើតថ្មីសំរាប់ប្រើប្រាស់ដល់ការចំណាយផ្តើមបង្កើត ឬគ្រឿងបរិក្ខារសំរាប់បំរើអោយឥណទាន ត្រឹមត្រូវចំពោះសហគ្រាសក្នុងស្រុក ឬសំរាប់ការប្រើប្រាស់គ្មានហានិភ័យផ្សេងទៀត ក្នុងក្របខ័ណ្ឌមុខរបរធនាគារ ។ មានតែប្រាក់ដកលំជានាស្មើនឹង ៥% នៃ ដើមទុនប៉ុណ្ណោះដែលត្រូវឃាត់មិនអោយប្រើទុកនៅធនាគារជាតិនៃកម្ពុជា ។

វិធីសំណុំលិខិតនៃគំរោង

ប្រការ២៥._ក្រៅពីខ្លឹមសារនៃសំណុំលិខិតដែលលើកឡើងក្នុងមាត្រាទី ១០_១២_១៣ ១៨ និង ១៩ ខាងលើ និងក្នុងករណីដែលពុំទាន់បានផ្តល់មកទេ ពតិមានឬលិខិតយុត្តិការនានាដែលរៀបរាប់ខាងក្រោមនេះចាំបាច់ត្រូវតែភ្ជាប់មកជាមួយនឹងពាក្យសុំអាជ្ញាប័ណ្ណ ឬជាមួយនឹងពាក្យសុំបន្តអាជ្ញាប័ណ្ណឡើងវិញគឺ :

១_ឯកសារយុត្តិកម្មនៃការបង្កើតនិយ័តរបស់ក្រុមហ៊ុនកំពុងផ្តើមបង្កើត ដែលនឹងក្លាយទៅជាធនាគារ ឬរបស់ក្រុមហ៊ុនដែលមានរួចមកហើយ ។

២_ឯកសារគណនេយ្យមានវិញ្ញាបនកម្ម ដែលបញ្ជាក់ភស្តុតាងពីសកម្មភាព និងស្ថានភាពហិរញ្ញវត្ថុនៃក្រុមហ៊ុនដែលមានអត្ថិភាពហើយ ហើយដែលនឹងក្លាយទៅជាធនាគារ ។

៣_លក្ខន្តិកៈ ឬ វិសោធនកម្មលក្ខន្តិកៈ ដែលបញ្ជាក់ជាអាទិ៍ទំរង់គតិយុត្តក្នុងចំណោមក្រុមហ៊ុនមូលធន និងពីការបែងចែកនៃដើមទុន និងសិទ្ធិបោះឆ្នោតតាមឈ្មោះភាគទុនិកម្នាក់ៗ ។

៤_បញ្ជីរាយនាមអ្នកដឹកនាំ និងសមាជិកនៃអង្គការដែលមានសិទ្ធិសំរេច ដោយភ្ជាប់ជាមួយ នូវជីវប្រវត្តិរបស់គេម្នាក់ៗ ហើយនិងឯកសារយោងស្តីពីកិត្តិភាពរបស់ពួកគេ ។ ចំពោះកិត្តិភាពក៏ដូចសមត្ថភាពមួយណាក៏ត្រូវមានលក្ខណៈពិតប្រាកដមិនអាចប្រកែកបាន ។

៥_ឯកសារបញ្ជាក់ពីភាពអាចដំណើរការបានភ្លាមនៃក្រុមមួយ ដែលអាចទទួលភារៈដឹកនាំធនាគារបានភ្លាមតាមតម្រូវការដូចជាកិច្ចសន្យាជ្រើសរើសយកអោយធ្វើការជាដើម ។

៦_ការរៀបរាប់កម្មវិធីសកម្មភាពសំខាន់ៗ និងការបង្ហាញភស្តុតាងខាងសេដ្ឋកិច្ចសំរាប់ប្រទេសកម្ពុជា ។

៧_គំរោងនៃស្ថានភាពហិរញ្ញវត្ថុសំរាប់ ៣ ការិយាយបរិច្ឆេទដំបូងគឺ ÷

_តារាងបង្ហាញគំរោងជាតួលេខធំៗ នៃប្រភពទុនក្រៅអំពីទាយជ្ជទាន (ប្រាក់បញ្ញើ_អន្តរធនាគារ បុនហិរញ្ញប្បទាន) និងនៃការប្រើប្រាស់ទុនដែលបែងចែកពីខ្ទង់មួយទៅខ្ទង់មួយ តាមជំពូក_រយៈកាលកំណត់ និងប្រភេទអតិថិជ

_តារាងបង្ហាញគណនីអាជីវកម្ម សំរាប់រយៈពេល ៣ឆ្នាំ ដូចគ្នា ។

៨_ការរៀបរាប់ពីបណ្តាញ «ធនាគារទំនាក់ទំនង»(CORPESPONDANTS) នៅបរទេស ដោយភ្ជាប់ច្បាប់ចម្លងនៃការយល់ព្រមធ្វើទំនាក់ទំនងរបស់ពួកគេផង ។

៩_ការវិវត្តន៍ព្រាងទុកនៃចំនួនបុគ្គលិកតាមប្រភេទ (អ្នកដឹកនាំ_ក្របខ័ណ្ឌ_និយោជិត) និងការគ្រោងជាតួលេខចំណាយប្រចាំឆ្នាំ ដែលត្រូវរ៉ាប់រង (ដោយស្របទៅនឹង គំរោងគណនីអាជីវកម្ម) ។

១០_ការរៀបរាប់អំពីមធ្យោបាយសម្ភារៈដែលគ្រោងទុក :

_អាស័យដ្ឋាន និងការរៀបរាប់អំពីទីតាំងនៃសាខា និងការបញ្ជាក់ពីចំនួន និងតាំងនៃអនុទីភ្នាក់ងារប្រសិនបើមាន ។

_ការរៀបចំពតិមានគណនេយ្យក្នុងព្យូទ័រ (Logiciels et matériels) ។

១១_ការរៀបរាប់ពីរចនាសម្ព័ន្ធ (អង្គការលេខ) និងវិធីត្រួតពិនិត្យ សាខាត្រួតពិនិត្យផ្ទៃក្នុង និងត្រួតពិនិត្យពីខាងក្រៅ (សវនការគណនី និងការពិនិត្យទូទាំងក្រុម ប្រសិនបើមាន) ។

១២_ការបញ្ជាក់ពីកាលបរិច្ឆេទដែលគ្រោងបើកដំណើរការសាខានៅកម្ពុជា ។

ប្រការ២៦ : រាល់ការបញ្ជាក់ដែលចែងនៅមាត្រាខាងលើ ត្រូវមានភស្តុតាងជាលាយលក្ខអក្សរ ជាតួលេខនិងមានចុះហត្ថលេខា ដើម្បីញ៉ាំងអោយការបញ្ជាក់ទាំងនោះមានភាពជាក់លាក់ ។

ប្រការ២៧ : បើបើកក្រោមទំរង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុក ធនាគារកំពុងបង្កើតនិងធនាគារកំពុងធ្វើសកម្មភាពត្រូវទំនាក់ទំនងក្នុងពេលដ៏សមស្រប ជាមួយធនាគារជាតិ ដើម្បីកសាងសំណុំលិខិតត្រឹមត្រូវ នៃការស្នើសុំអាជ្ញាប័ណ្ណឬប្រសិនបើមាន នៃការស្នើសុំបន្តអាជ្ញាប័ណ្ណឡើងវិញ ។

ប្រការ២៨ : ធនាគារប្រតិស្រុតទាំងឡាយ ត្រូវតែជូនដំណឹងអោយអាជ្ញាធរអាណាព្យាបាលជាមុន អំពីការប្រែប្រួលទាំងអស់ ដែលនឹងអាចកើតឡើងចំពោះសមាសភាពនៃភាគទុនិក ឬការគ្រប់គ្រងធនាគារ និងដែលមានឥទ្ធិពលប្រែប្រួលដល់រាល់លក្ខខ័ណ្ឌ ដែលប្រកាន់ទុកជាមុន ដោយធនាគារជាតិនៃកម្ពុជា ក្នុងការចេញអាជ្ញាប័ណ្ណអោយ ។

ប្រការ២៩ : ខុទ្ទកាល័យ គ្រប់នាយកដ្ឋាន និងគ្រប់ធនាគារពាណិជ្ជកម្ម ក្រោមឱវាទធនាគារជាតិនៃកម្ពុជា មានភារកិច្ចអនុវត្តយ៉ាងម៉ឺងម៉ាត់តាមប្រកាសនេះ ។

ប្រការ៣០.– ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសាភិបាល

ហត្ថលេខា និងត្រា

ថៅ ច័ន្ទលាភ

* * *

៣–ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

ភ្នំពេញ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣១៤ ពណពកប.ប្រក

* * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

– ក្នុងគោលបំណងអនុវត្តការផ្តល់វិញ្ញាបនប័ត្រប្រភពទំនិញទំរង់ "A" អោយបានត្រឹមត្រូវ តាមបទបញ្ញត្តិប្រព័ន្ធអនុគ្រោះទូទៅ (EC) 1417/97

សម្រេច

ប្រការ ១._ផ្តល់វិញ្ញាបនប័ត្រប្រភពដើមទំរង់ " A" ជូនក្រុមហ៊ុនកាត់ដេរតាមលក្ខខ័ណ្ឌ ដូចខាងក្រោម :

ក_ទំនិញសំលៀកបំពាក់ទាំងឡាយណាដែលបានផលិតនៅព្រះរាជាណាចក្រកម្ពុជា អំពីក្រណាត់ និងវត្ថុធាតុដើមដែលមានប្រភពដើម ពីបណ្តាប្រទេសស្ថិតនៅក្នុងក្រុមសេដ្ឋកិច្ចតំបន់ ដូចតទៅ :

_អាស៊ាន (ASEAN) លើកលែងតែភូមា : ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី វៀតណាម ឡាវ ប្រុយណេ ថៃ ឥណ្ឌូនេស៊ី ។

_ក្រុមប្រទេសសហគមន៍អាស៊ីខាងត្បូង (SAARC) : បង់ក្លាដេស ស្រីលង្កា ឥណ្ឌា ប៊ុយតានម៉ាល់ឌីវ នេប៉ាល ប៉ាគីស្ថាន ។

_ក្រុមប្រទេសសមាជិកនៃសន្ធិសញ្ញា អាហ្វ្រិក បណ្តាប្រទេសតំបន់ការ៉ាអ៊ីប និង ប៉ាស៊ីហ្វិក (ACP) ។

ខ_ក្រុមហ៊ុនត្រូវចុះបញ្ជី GSP នៅការិយាល័យប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នៃក្រសួង ពាណិជ្ជកម្ម ។

គ_វត្ថុធាតុដើម និងក្រណាត់នាំចូល ត្រូវអមដោយវិញ្ញាបនប័ត្រប្រភពដើម ដែលចេញ អោយដោយអាជ្ញាធរនៃប្រទេសដែលបានរៀបរាប់ខាងលើ ហើយវត្ថុធាតុដើម និងក្រណាត់នោះ ត្រូវបញ្ជាក់អោយបានច្បាស់លាស់នូវលេខកូដនៃប្រព័ន្ធ H.S ។

ប្រការ២._ការិយាល័យប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវសរសេរបន្ថែមនូវឃ្លា " Derogation (EC) 1417/97 " នៅក្នុងប្រអប់លេខ ៤ នៃវិញ្ញាបនប័ត្រទំរង់ "A" ។

ប្រការ៣._ក្រសួងពាណិជ្ជកម្មធ្វើការបែងចែក Quota ជាបន្តបន្ទាប់ជូនក្រុមហ៊ុន ទាំងអស់ ដោយផ្អែកតាមសមត្ថភាពផលិតនិងការធ្វើអាជីវកម្មជាក់ស្តែងរបស់ក្រុមហ៊ុននិមួយៗ ។

ប្រការ ៤._ប្រកាសនេះមានអនុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខានិងត្រា

ចម ប្រសិទ្ធិ

៤_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពតិមាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២៨៨/៩៧ ព.ម.ប្រក

ស្ដីពីការតែងតាំងមន្ត្រីរាជការក្រសួងពតិមាន

=====

រដ្ឋមន្ត្រីក្រសួងពតិមាន

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

_បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងពតិមាន

_យោងតាមតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋានកាសែតកម្ពុជា

_ពិនិត្យលើលក្ខណសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក **លី ទ៉ាន់ហុន** ជាប្រធានការិយាល័យទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងរោងពុម្ពអគ្គនាយកដ្ឋានកាសែតកម្ពុជា នៃក្រសួងពតិមាន ។

ប្រការ២ : ឯកឧត្តមអគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ ឯកឧត្តមអគ្គនិពន្ធនាយកកាសែតកម្ពុជា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការគណ

នេយ្យហិរញ្ញកិច្ច និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២៨៩/៩៧ ព.ម.ប្រក

ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦-១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងតាមតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋានឯកសារបណ្ណាល័យ
- ពិនិត្យលើលក្ខណសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ១ : តែងតាំងលោក ជុក សារី ជាអនុប្រធាននាយកដ្ឋានឯកសារបណ្ណាល័យ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងពត៌មាន ។

ប្រការ២ : ឯកឧត្តមអគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការគណនេយ្យហិរញ្ញកិច្ច និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២៩០/៩៧ ព.ម.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការក្រសួងពត៌មាន

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦_១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងតាមសំណើរបស់នាយកដ្ឋានរដ្ឋបាល
- ពិនិត្យលើលក្ខណសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក **ហ៊ឿន សម្បត្តិ** ជាអនុប្រធាននាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងពត៌មាន ។

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញកិច្ច និងសាម៉ីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២៩១/៩៧ ព.ម.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦_១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងតាមសំណើរបស់នាយកដ្ឋានមណ្ឌលពត៌មាន
- ពិនិត្យលើលក្ខណសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ៣ រូប ជាអនុប្រធានការិយាល័យ នាយកដ្ឋានមណ្ឌលពត៌មាន អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោមនេះ :

១/_លោក ម៉ម ម៉ារី ជាអនុប្រធានការិយាល័យបែងចែកពតិមាន

២/_លោក ឡេង ស៊ីថា ជាអនុប្រធានការិយាល័យបែងចែកពតិមាន

៣/_កញ្ញា ជុំ សុវណ្ណសូលីដា ជាអនុប្រធានការិយាល័យប្រភពជំណឹង

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានមណ្ឌលពតិមាន ប្រធាននាយកដ្ឋានផែនការគណនេយ្យហិរញ្ញកិច្ច និងសាមីខ្លួនក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ឡេង ភាព្យារិទ្ធ

* * *

រាជធានីភ្នំពេញ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២៩២/៩៧ ព.ម.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពតិមាន

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

_បានឃើញព្រះរាជក្រម នស.រកម ០១៩៦_១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពតិមាន

_យោងតាមសំណើរបស់នាយកដ្ឋានមណ្ឌលពតិមាន

_ពិនិត្យលើលក្ខណសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ១ : តែងតាំងលោក **ម៉ាក់ គន្ធលី** ជាអនុប្រធាននាយកដ្ឋានមណ្ឌលពតិមាន ទទួលបន្ទុកបែងចែកពតិមាន អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងពតិមាន ។

ប្រការ២ : ឯកឧត្តមអគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានមណ្ឌលពតិមាន ប្រធាននាយកដ្ឋានផែនការគណនេយ្យហិរញ្ញកិច្ច និងសាមីខ្លួនក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល